ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍ប្រចាំឆ្នាំ២០១៥









**រៀបចំដោយ:**

ក្រុមការងារកិច្ចការពារសុវត្ថិភាព បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
នៃលេខាធិការដ្ឋាន គ.ជ.អ.ប

ខែធ្នូ ឆ្នាំ២០១៥

# មាតិកា

**ទំព័រ**

**១.សេចក្តីផ្តើម**........................................................................................................១
**២.សកម្មភាព និងលទ្ធផលសម្រេចបាន**.......................................................................................២

២.១.ការពិនិត្យបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ ដែលត្រូវការសិក្សាកិច្ចការពារសុវត្ថិភាព............២
២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៥........................................................២
២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៥........................................................៣
២.១.៣.បញ្ជីគម្រោងមូលនិធិរាជធានី ខេត្ត ឆ្នាំ២០១៥....................................................៣
២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោង ឆ្នាំ២០១៥..................................................៤
២.២.១.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងឃុំ សង្កាត់ ឆ្នាំ២០១៥.................៤
២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងក្រុង ស្រុក ឆ្នាំ២០១៥.................៤
២.២.៣.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងរាជធានី ខេត្ត ឆ្នាំ២០១៥.............៥
២.៣.ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃឆ្នាំ២០១៤... .......................៤
២.៤.ការពង្រឹងសមត្ថភាព.............................................................................................៦
២.៥.សកម្មភាពពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ ........................................................៦
២.៦.ការគាំទ្រ និងកិច្ចសហការ.......................................................................................៨

**៣.បញ្ហាប្រឈមនានា**........................................................................................................៩
**៤.ការសន្និដ្ឋាន**.............................................................................................................១០
**៥.អនុសាសន៍ និងសំណូមពរ**..........................................................................................១០
**៦.សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៦**.............................................................................១១
**៧.ឧបសម្ព័ន្ធ៖**
៧.១. បញ្ជីសង្ខេបគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ ដែលត្រូវការសិក្សាកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
៧.២. តារាងតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក និងរាជធានី ខេត្ត ឆ្នាំ២០១៥
៧.៣. បញ្ជីឈ្មោះមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពទាំងបីឆ្នាំ២០១៥
៧.៤. រូបថតសកម្មភាពក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច

## ១. សេចក្ដីផ្ដើម

ផែនការអនុវត្តដំណាក់កាលទី១(២០១១-២០១៤) ផ្ដោតការយកចិត្តទុកដាក់ទៅលើការពង្រឹង និង ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ឱ្យក្លាយជាស្ថាប័នអភិបាលកិច្ចមូលដ្ឋាន និងអភិវឌ្ឍមូលដ្ឋានយ៉ាងពិតប្រាកដ។ មូលដ្ឋានគ្រឹះសំខាន់ៗ ដូចជារចនាសម្ព័ន្ធ នីតិវិធី ប្រព័ន្ធ និងឧបករណ៍ជាច្រើនសម្រាប់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងវិញ និងបានផ្ដល់ជាបង្អែកយ៉ាងរឹងមាំសម្រាប់ការបោះជំហានឆ្ពោះទៅមុខ។ ទាំងនេះបណ្ដាលឱ្យផអ៣ទី១ ក្លាយជាកម្លាំងចលករមួយដ៏សំខាន់សម្រាប់ការងារកំណែទម្រង់ និងជាសនិទានកម្មដ៏សំខាន់ដែលនាំឱ្យរាជរដ្ឋាភិបាលបានសម្រេចចិត្តអនុវត្តដំណាក់កាលទី២ (ផអ៣ទី២)តាមរយៈកិច្ចប្រជុំលើកទី១០ របស់គ.ជ.អ.ប កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ដែលចាប់ផ្ដើមពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។

ចក្ខុវិស័យនៃផអ៣ទី២នេះ គឺ "*រដ្ឋបាលថ្នាក់ក្រោមជាតិផ្ដល់សេវា និងអភិវឌ្ឍមូលដ្ឋានបានកាន់តែច្រើន កាន់តែល្អប្រសើរ កាន់តែមានលក្ខណៈឆ្លើយតបចំពោះសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន*"។ ស្រដៀងគ្នានឹងផអ៣ទី១ ផអ៣ទី២ បន្តផ្ដោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើរដ្ឋបាលក្រុង ស្រុក ប៉ុន្តែក៏មានការពាក់ព័ន្ធជាមួយនឹងថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀតផងដែរ។ ទាក់ទងជាមួយភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ ក្នុងក្របខណ្ឌផអ៣ទី២ នឹងមិនអនុវត្តដោយអនុកម្មវិធីទៀតទេ។ ភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ គឺជាក្រសួង ស្ថាប័នទាំងឡាយណាដែលមានការពាក់ព័ន្ធជាមួយការងារកំណែទម្រង់ ជាពិសេសការផ្ទេរមុខងារ និងធនធានក្នុងការផ្ដល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។

ចក្ខុវិស័យសម្រាប់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺការប្រើប្រាស់ធនធានទាំងអស់ដែលមានរួមទាំងមន្ត្រីរាជការស៊ីវិល បុគ្គលិកកិច្ចសន្យា ទាំងផ្នែកឯកជន និងអង្គការសង្គមស៊ីវិល។ ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅរាជធានី ខេត្ត គឺជាយន្តការថ្មីមួយទៀតនៃផអ៣ទី២ ដែលសង្ឃឹមថានឹងធានាបាននូវការរៀបចំវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពដែលមានលក្ខណៈឆ្លើយតប និងប្រកបដោយការផ្ដួចផ្ដើមសំដៅសម្រេចបានដោយជោគជ័យក្នុងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការពារសុវត្ថិភាពជាយន្តការមួយត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ។យន្តការមួយនេះ ត្រូវបានប្រើប្រាស់នៅក្នុងសៀវភៅណែនាំ ស្ដីពីការអនុវត្តគម្រោង ដែលតម្រូវឱ្យអ្នកអនុវត្តគម្រោងត្រូវតែមានការប្រុងប្រយ័ត្នជាមុនលើហានិភ័យដែលអាចកើតមានឡើងដោយសារការអនុវត្តគម្រោងលើកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច មានន័យថា គោលបំណងសំខាន់នៃកិច្ចការពារសុវត្ថិភាពទាំងនេះ គឺការជៀសវាងបានឬកាត់បន្ថយបានជាអប្បបរមា ឬក៏សម្រាលបន្ទុកនៃផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន ឬចំណាយសង្គម ចំពោះភាគីទីបី ឬពុំអើពើចំពោះក្រុមជនងាយរងគ្រោះ ដែលអាចទទួលរងឥទ្ធិពលពីគម្រោងអភិវឌ្ឍន៍មូលដ្ឋាន។

កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានក្លាយជាប្រធានបទមួយយ៉ាងសំខាន់សម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ដែលលេខាធិការដ្ឋាន គ.ជ.អ.ប បានពិចារណាយ៉ាងល្អិតល្អន់លើដំណោះស្រាយបញ្ហាបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាអាទិភាពសម្រាប់គ្រប់គម្រោងអភិវឌ្ឍន៍ទាំងអស់នៅថ្នាក់ក្រោមជាតិ។

ក្នុងឆ្នាំ២០១៥នេះ ក្រុមការងារកិច្ចការពារសុវត្ថិភាពបានអនុវត្តតាមផែនការសកម្មភាព និងថវិកា ហើយសម្រេចបានលទ្ធផលមួយចំនួនមានដូចជា៖ តាមរយៈការប្រជុំប្រចាំឆ្នាំ និងតាមរយៈវគ្គបណ្ដុះបណ្ដាលស្ដីពីមូលដ្ឋានគ្រឹះគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ ផ្សារភ្ជាប់ជាមួយវគ្គបណ្ដុះបណ្ដាលរំលឹកឡើងវិញដល់មន្ត្រីបច្ចេកទេសដែលទើបចូលបម្រើការងារថ្មី និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចថ្នាក់ខេត្តពីដំណើរការ និងគោលការណ៍ នៃការអនុវត្តកិច្ចការពារសុវត្ថិភាពទាំងបី ព្រមទាំងបានចែករំលែកមេរៀន និងបទពិសោធន៍ល្អៗដល់អ្នកពាក់ព័ន្ធនានាផងដែរ។ ការពិនិត្យ និងផ្ដល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍វិភាគ

ផលប៉ះពាល់បរិស្ថាន និងរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ព្រមទាំងការចុះពង្រឹងការអនុវត្តកិច្ចការពារសុវត្ថិភាពជាក់ស្តែងនៅតាមបណ្តាឃុំ សង្កាត់ និងនៅទីតាំងគម្រោង ដោយបានជួបជាមួយមន្ត្រីពាក់ព័ន្ធ ដូចជា ទីប្រឹក្សាខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង។ លើសពីនេះ ក្រុមការងារបានសម្របសម្រួលជាមួយនាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ និងបានធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងឆ្នាំ២០១៥ ជារៀងរាល់ខែដែលថ្នាក់ក្រោមជាតិបានសិក្សាមុន នឹងអនុវត្តន៍គម្រោង។ ជាមួយគ្នានេះដែរ ក្រុមការងារបានជួយពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសារ និងរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន របាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច តាមគោលការណ៍ណែនាំក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត និងតាមបទដ្ឋាននានាមុននឹងដេញថ្លៃគម្រោង។ ក្រុមការងារ បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំស្តីពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងឃុំ សង្កាត់ ក្រុង ស្រុក និងរាជធានី ខេត្ត ដល់ថ្នាក់ក្រោមជាតិដែលជាអ្នកអនុវត្តគម្រោងផ្ទាល់ ដើម្បីបានពិភាក្សាផ្លាស់ប្តូរផ្តល់យោបល់គ្នា លើការអនុវត្តកិច្ចការពារសុវត្ថិភាពទាំងបីបានសមស្រមតាមសៀវភៅគោលការណ៍ណែនាំនិងមានប្រសិទ្ធភាព។

## ២. សកម្មភាព និងលទ្ធផលសម្រេចបាន

**២.១.ការពិនិត្យបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ឆ្នាំ២០១៥ ដែលត្រូវការសិក្សាសុវត្ថិភាព ៖**

**២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៥ ៖**

គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៥ មានចំនួនសរុប **១៦៦៧**គម្រោង នៃ**១៥៣៧**ឃុំ សង្កាត់ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន **៦៥០**គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន **៦២២**គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន **៩០**គម្រោង។ គម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប**៥៦០** និងគម្រោងដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចមានចំនួនសរុប ៩០គម្រោង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៤ ។

**រូបភាពទី១៖ ក្រាហ្វិចចំនួនឃុំសង្កាត់ និងចំនួនគម្រោងតម្រូវការសិក្សាសុវត្ថិភាព**



នៅក្នុងគម្រោងសរុបចំនួន**១៦៦៧**នេះ មានផ្លូវគ្រប់ប្រភេទចំនួន **១៣៩០**ខ្សែ ស្ពានចំនួន **៣០**កន្លែង ប្រព័ន្ធជាពសាស្ត្រមានប្រឡាយ និងទំនប់ចំនួន **១៥៦**កន្លែង អណ្តូងស្នប់ និងស្រះដីកចំនួន **១៩**កន្លែង សាលារៀនចំនួន **២៣**កន្លែង បង្គន់ចំនួន **៥**កន្លែង និងផ្សេងៗដែលមានប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹក សំណង់ទីទួលសុវត្ថិភាព សំណង់ស្ថានីយ៍បូមទឹក ផែសហគមន៍ រនេលស្ទាក់ទឹក និងរ៉ទឹកចំនួន **៥៣**កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្តន៍។

**រូបភាពទី២៖ ក្រាហ្វិចឈ្មោះគម្រោង និងចំនួនគម្រោងឃុំ សង្កាត់ ឆ្នាំ២០១៥**




### ២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៥ ៖

គម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៥ មានចំនួនសរុប**២៤៨** គម្រោងនៃ **១៨៥**ក្រុង ស្រុក។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន ៩០គម្រោង តម្រូវការសិក្សាជីផ្លីសរុបចំនួន ៨គម្រោង តម្រូវការសិក្សាជនជាតិដើមភាគតិចមាន ១៨គម្រោង។ ចំនួនគម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុប៨៣។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើងនៅក្នុងខេត្តទាំង២៤ ។

**រូបភាពទី៣៖ ក្រាហ្វិចចំនួនគម្រោង និងតម្រូវការសិក្សាសុវត្ថិភាពគម្រោងក្រុង ស្រុកឆ្នាំ២០១៥**




នៅក្នុងគម្រោងសរុបចំនួន២៤៨នេះ មានផ្លូវគ្រប់ប្រភេទចំនួន **១៥៤**ខ្សែ ស្ពានចំនួន **៧**កន្លែង ប្រព័ន្ធជាពសាស្ត្រមានប្រឡាយ និងទំនប់ចំនួន ៨កន្លែង អណ្តូងស្នប់ចំនួន ១កន្លែង ជួសជុលអគាររដ្ឋបាលចំនួន ១០កន្លែង និងផ្សេងៗដែលមានប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹក កែលម្អសួន របងអាគារ ចាក់សាបទីធ្លាសាធារណៈចំនួន **៣៨**កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្តន៍។

រូបភាពទី៤៖ ក្រាហ្វិចឈ្មោះគម្រោង និងចំនួនគម្រោងក្រុង ស្រុក ឆ្នាំ២០១៥




២.១.៣.បញ្ជីគម្រោងមូលនិធិរាជធានី ខេត្ត ឆ្នាំ២០១៥ ៖

គម្រោងមូលនិធិរាជធានី ខេត្ត ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៥ មានចំនួនសរុប **២៧០**គម្រោង នៃខេត្តទាំង២៤ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន **៣០**គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន **៣**គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចចំនួន **៧**គម្រោង។ គម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប៣០។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងខេត្តដែលបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៤ ។

រូបភាពទី៥៖ ក្រាហ្វិចចំនួនគម្រោង និងតម្រូវការសិក្សាសុវត្ថិភាពគម្រោងខេត្តឆ្នាំ២០១៥




នៅក្នុងគម្រោងសរុបចំនួន**២៧០**នេះ មានផ្លូវគ្រប់ប្រភេទចំនួន **៧៦**ខ្សែ ស្ពានចំនួន **១**កន្លែង ប្រព័ន្ធធារាសាស្ត្រមានចំនួន **៦**គម្រោង អគាររដ្ឋបាលចំនួន **២៥**កន្លែង និងផ្សេងៗដែលមានប្រព័ន្ធលូ ជួសជុល និងសាងសង់បង្គោលភ្លើងបំភ្លឺផ្លូវ ថៃលម្អសួនច្បារសាធារណៈចំនួន **១០៦**កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្តន៍។

រូបភាពទី៦៖ ក្រាហ្វិចឈ្មោះគម្រោង និងចំនួនគម្រោងខេត្ត ឆ្នាំ២០១៥



### ២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោង ឆ្នាំ២០១៥៖

#### ២.២.១.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ ៖

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថានចំនួនសរុប ៥៣៤គម្រោង ស្មើនឹង៩៣%នៃចំនួនសរុប ៥៧៤គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចចំនួន ៧៨គម្រោង ស្មើនឹង៨៦%នៃចំនួន៩០គម្រោង ដែលស្ថិតក្នុងបញ្ជីជនជាតិដើមភាគតិច។ ក្នុងនេះ គម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅមូលដ្ឋានមានចំនួន ៩គម្រោង។

រូបភាពទី៧៖ ក្រាហ្វិចចំនួនគម្រោង និងភាគរយដែលបានពិនិត្យ គម្រោងឃុំ សង្កាត់ឆ្នាំ២០១៥




#### ២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិក្រុង ស្រុក៖

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិក្រុង ស្រុក លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីងាយរងទទួលផលប៉ះពាល់បរិស្ថានចំនួនសរុប ៥៧គម្រោង ស្មើនឹង៦៩%នៃចំនួនសរុប ៨៣គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចចំនួន ៨គម្រោង ស្មើនឹង៤៤%នៃចំនួន ១៨គម្រោងដែលស្ថិតក្នុងបញ្ជីជនជាតិដើមភាគតិច។

រូបភាពទី៨៖ ក្រាហ្វិចចំនួនគម្រោង និងភាគរយដែលបានពិនិត្យ គម្រោងក្រុង ស្រុកឆ្នាំ២០១៥




#### ២.២.៣.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិរាជធានី ខេត្ត៖

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថានចំនួនសរុប ២៩គម្រោង ស្មើនឹង៩៧%នៃចំនួនសរុប

៣០គម្រោង និងផ្ដល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចចំនួន **៥**គម្រោង **ស្មើ៧១%**នៃចំនួន **៧**គម្រោង។

**រូបភាពទី៩៖ ក្រាហ្វិចចំនួនគម្រោងខេត្តឆ្នាំ២០១៥ និងភាគរយដែលបានពិនិត្យ**




**២.៣.ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃគម្រោងឆ្នាំ២០១៤ ៖**

បានចុះត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីរបស់គម្រោងនៅទីចាត់ការផែនការ និងវិនិយោគខេត្តចំនួនប្រាំបួន ព្រមទាំងបានចុះទៅដល់ឃុំ សង្កាត់ និងទីតាំងគម្រោង។ ក្នុងខេត្តទាំងប្រាំបួននេះ បានត្រួតពិនិត្យគម្រោង ដីធ្លីសរុបចំនួន **១៦៩**គម្រោង ស្មើនឹង**៦៥%**នៃគម្រោងមូលនិធិឃុំ សង្កាត់ ត្រូវការសិក្សាដីធ្លីសរុបចំនួន **២៥៧**គម្រោង។ ដំណើរការនៃការត្រួតពិនិត្យឯកសារ និងរបាយការណ៍ដីធ្លីនេះ ធ្វើឡើងនៅទីចាត់ការផែនការ និងវិនិយោគខេត្ត និងសាលាឃុំ សង្កាត់ ហើយផ្ទៀងផ្ទាត់របាយការណ៍ទាំងនោះ នៅតាមទីតាំងគម្រោង ដោយជួបជាមួយប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង។ បន្ទាប់ពីបញ្ចប់រាល់ការពិនិត្យឯកសារ ក្រុមការងារបានប្រជុំឆ្លុះបញ្ចាំងដោយបានបង្ហាញពីលទ្ធផលដែលរកឃើញដល់នាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគ ព្រមទាំងមន្ត្រីទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងទីប្រឹក្សាខេត្តពាក់ព័ន្ធ ដើម្បីផ្ដល់យោបល់លើចំណុចខ្វះខាតដែលជាមេរៀននិងបទពិសោធន៍សម្រាប់អនុវត្តនៅឆ្នាំក្រោយៗទៀត។ តារាងខាងក្រោមបង្ហាញពីចំនួនឯកសាររបាយការណ៍សិក្សាដីធ្លី ដែលក្រុមការងារបានត្រួតពិនិត្យ។

**តារាងទី១៖ ចំនួនគម្រោងឆ្នាំ២០១៤ដែលសិក្សាដីធ្លី និងភាគរយដែលបានចុះត្រួតពិនិត្យ**

| ល.រ | ឈ្មោះខេត្ត | ចំនួនគម្រោងសរុប | ចំនួនគម្រោងត្រូវការសិក្សាដីធ្លី | គម្រោងត្រូវបានពិនិត្យ | ចំនួន% |
|---|---|---|---|---|---|
| ១ | កំពត | ៩៧ | ៧២ | ២៨ | ៣៩% |
| ២ | កំពង់ចាម | ១២២ | ២៥ | ២៥ | ១០០% |
| ៣ | ព្រៃវែង | ១២៥ | ៤៧ | ២៧ | ៦០% |
| ៤ | ស្ទឹងត្រែង | ២២ | ៥ | ៥ | ១០០% |
| ៥ | តាកែវ | ១០៥ | ៦០ | ៣៨ | ៦៦% |
| ៦ | កែប | ៥ | ៤ | ៤ | ១០០% |
| ៧ | ពោធិ៍សាត់ | ៥៤ | ២២ | ២២ | ១០០% |
| ៨ | ឧត្ដរមានជ័យ | ២៥ | ៧ | ៧ | ១០០% |
| ៩ | សៀមរាប | ១០៤ | ១៥ | ១៣ | ៨៧% |
| **សរុប** | | **៦៥៩** | **២៥៧** | **១៦៩** | **៦៥%** |

## ២.៤. ការពង្រឹងសមត្ថភាព៖

- ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ បានចូលរួមក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ នៃគ.ជ.អ.ប និងចូលរួមពិភាក្សាលើសេចក្តីព្រាងសៀវភៅណែនាំស្តីពីការរៀបចំគម្រោងសេវាសង្គមក្រុង ស្រុក និងកិច្ចប្រជុំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ នៃគ.ជ.អ.ប។
- ថ្ងៃទី៤-៥ ខែកុម្ភៈ ឆ្នាំ២០១៥ បានចូលរួមក្នុងកិច្ចប្រជុំលើកទី១០ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកិច្ចប្រជុំផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប។
- ថ្ងៃទី១៤-១៧ ខែសីហា ឆ្នាំ២០១៥ បានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយនិងកសាងសមត្ថភាពស្តីពីការបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ក្រោមជាតិ ដែលរៀបចំដោយគម្រោងLGCCII គាំទ្រដោយអង្គការ UNCDF ប្រចាំកម្ពុជា រៀបចំនៅខេត្តព្រះសីហនុ។
- ថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៥ បានចូលរួមក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប នៅខេត្តព្រះសីហនុ។

## ២.៥. សកម្មភាពពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ៖

### ក.នៅខេត្តព្រះសីហនុ៖

ថ្ងៃទី១៨-១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០១៥ ភ្ជាប់ជាមួយនិងវគ្គរំលឹកឡើងវិញស្តីពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់នៅខេត្តព្រះសីហនុ ដែលមានសមាសភាពចូលរួមជានាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីការិយាល័យផែនការ និងគាំទ្រគម្រោងឃុំ សង្កាត់ និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពខេត្ត សរុបចំនួន៥៧ នាក់ស្រី ២នាក់។ គោលបំណងនៃកិច្ចប្រជុំ គឺដើម្បីកែលម្អនូវចំណុចខ្វះចន្លោះមួយចំនួន ដែលបានរកឃើញក្នុងរយៈពេលអនុវត្តការងារ១០ខែកន្លងទៅ និងឆ្លើយតបចំពោះតម្រូវការជាក់ស្តែងនៅថ្នាក់ក្រោមជាតិ ដោយផ្សារភ្ជាប់និងវគ្គរំលឹកឡើងវិញស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ រួមទាំងគម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ដោយផ្តោតជាសំខាន់ទៅលើចំណុចបីគឺ៖

១-ពិនិត្យមើលពីវឌ្ឍនភាពនៃការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៥ រួមទាំងគម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ផងដែរ។

២-សិក្សាស្វែងយល់អំពីបញ្ហាប្រឈមនានា ដើម្បីរួមគ្នាពិភាក្សា រកដំណោះស្រាយ និងលើកទិសដៅបន្ត និងផ្តល់ព័ត៌មានត្រលប់វិញ ព្រមទាំងផ្តល់អនុសាសន៍នានា ដល់មន្ត្រីពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិលើការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានា។

៣- ពង្រឹងយន្តការគាំទ្រ តាមដាន និងត្រួតពិនិត្យលើកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងការអនុវត្តគម្រោងរបស់មន្ត្រីពាក់ព័ន្ធនានានៅថ្នាក់ក្រោមជាតិ។

កិច្ចប្រជុំអស់រយៈពេលពីរថ្ងៃទទួលបានលទ្ធផលជាផ្លែផ្កាមួយចំនួន ដោយអ្នកចូលរួមទាំងអស់បានពិភាក្សាគ្នាផ្លាស់ប្តូរយោបល់ លើកឡើងនូវបទពិសោធន៍ល្អៗមួយចំនួនដែលទទួលបានជោគជ័យ ចំណុចមិនបានទទួលជោគជ័យមួយចំនួនដើម្បីពង្រឹងកិច្ចការពារសុវត្ថិភាពឱ្យបានល្អ។ ចំណុចល្អៗដែលខេត្តមួយចំនួនអនុវត្តទទួលបានជោគជ័យមានដូចខាងក្រោម៖

- បានអនុវត្តន៍តាមគោលការណ៍ណែនាំរបស់សៀវភៅ (ភីម)
- មានការណែនាំបង្ហាញពីថ្នាក់ជាតិច្បាស់លាស់
- មានផែនការសកម្មភាព និងថវិកាជាក់លាក់
- មានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ
- បានចុះសិក្សាភូមិសាស្ត្រ និងទីតាំងគម្រោង
- បានចុះតាមដាន និងត្រួតពិនិត្យវាយតម្លៃគម្រោង
- មានការយកចិត្តទុកដាក់លើការងារ។

អង្គពិភាក្សាបានលើកយកចំណុចមិនទទួលបានជោគជ័យមួយចំនួនមកពិភាក្សារកដំណោះស្រាយកែលម្អដើម្បីពង្រឹងកិច្ចការពារសុវត្ថិភាពឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តគម្រោង ក្នុងនោះរួមមាន៖

- ខេត្តមួយចំនួនមិនបានអនុវត្តន៍តាមគោលការណ៍ណែនាំសៀវភៅ(ភីម)
- មន្ត្រីទីចាត់ការផែនការ និងវិនិយោគមានចំនួនតិច មានការងារស្ទួលច្រើន និងមានការផ្លាស់ប្តូរមន្ត្រីជាញឹកញាប់
- ខ្វះសម្ភារៈ ខ្វះប្រេង និងមធ្យោបាយសម្រាប់សិក្សាគម្រោង ហើយសម្ភារៈ និងមធ្យោបាយទាំងនោះមានសភាពចាស់ទ្រុឌទ្រោម
- ការពិនិត្យបញ្ជាក់បច្ចេកទេសពីមន្ទីរវិស័យជំនាញមានភាពយឺតយ៉ាវទុករយៈពេលយូរ
- ខ្វះការតាមដានលើការអនុវត្តគម្រោង
- មន្ទីរជំនាញពាក់ព័ន្ធមួយចំនួនមិនសូវមានសហការក្នុងការសិក្សាគម្រោង
- មានភាពយឺតយ៉ាវក្នុងការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
- ការរៀបចំឯកសារ ពីថ្នាក់ក្រោមមានភាពយឺតយ៉ាវ
- មន្ត្រីថ្មីខ្វះជំនាញបច្ចេកទេសសិក្សាវិភាគផលប៉ះពាល់។

ដើម្បីពង្រឹងកិច្ចការពារសុវត្ថិភាពឱ្យបានល្អនាពេលខាងមុខ សមាជិក សមាជិកានៃអង្គប្រជុំទាំងអស់បានលើកយកចំណុចមួយចំនួនបញ្ចូលក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦របស់ខេត្ត ដែលនឹងត្រូវអនុវត្តន៍នាពេលខាងមុខដែលមានដូចខាងក្រោម៖

- មានផែនការសកម្មភាព និងថវិកាច្បាស់លាស់
- ប្រជុំឆមាស និងប្រចាំឆ្នាំផ្សារភ្ជាប់និងវគ្គរំលឹកឡើងវិញ
- មានសម្ភារៈ និងមធ្យោបាយគ្រប់គ្រាន់សម្រាប់សិក្សាគម្រោង
- បង្កើនការលើកទឹកចិត្តដល់មន្ត្រី និងជំរុញលើកទឹកចិត្តឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ
- បន្ថែមចំនួនមន្ត្រីឱ្យបានគ្រប់គ្រាន់តាមរចនាសម្ព័ន្ធ
- ពង្រឹងការអនុវត្តតាមការណែនាំ
- ចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង
- ស្នើសុំថ្នាក់ជាតិបន្ថែមនូវប្រាក់លើកទឹកចិត្តដល់មន្ត្រី
- រដ្ឋបាលក្រុងស្រុកត្រូវពង្រឹងយន្តការគាំទ្រដល់ឃុំ សង្កាត់។

អ្នកចូលរួមក្នុងកិច្ចប្រជុំ អ្នកចូលរួមបានលើកសំណូមពរដល់ក្រុមការងារ មានដូចជា៖

- គួរបន្ថែមចំនួនអ្នកចូលរួមក្នុងកិច្ចប្រជុំនៅលើកក្រោយៗមានចំនួនច្រើនជាងនេះ ដោយមានអ្នកចូលរួមពីខេត្តនីមួយៗចំនួនបួននាក់ ដែលមានសមាសភាពជានាយក ឬនាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាកសាង និងអភិវឌ្ឍន៍សមត្ថភាពខេត្ត ឬទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពខេត្ត ។
- គួរឱ្យមានមធ្យោបាយធ្វើដំណើររួមជាមួយអ្នកបើកបររបស់ខេត្តចូលរួមប្រជុំដោយប្រើប្រាស់ថវិការបស់ខេត្ត។

**ខ.នៅខេត្តកំពង់ចាម៖**

នៅខេត្តកំពង់ចាមថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ បានបង្រៀនវគ្គរំលឹកឡើងវិញស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត ដែលទើបចូលបម្រើការងារថ្មីមកពីរាជធានីខេត្តទាំង២៥ សរុបចំនួន ៦២នាក់។ វគ្គនេះផ្សារភ្ជាប់ជាមួយវគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ ដែលមានរយៈពេលប្រាំថ្ងៃ។ គោលបំណងនៃវគ្គនេះ គឺដើម្បីឆ្លើយតបក្នុងការជួយគាំទ្រដល់ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិដំណើរការដោយរលូន និងផ្តល់ចំណេះដឹង រួមទាំងបទពិសោធន៍លើការសិក្សាកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធថ្មីក្នុងការគាំទ្រគម្រោង។

**២.៦. ការគាំទ្រ និងកិច្ចសហការ៖**

- ក្រុមការងារបានសម្របសម្រួលជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្តទាំងអស់ដើម្បីពន្លឿនការសិក្សាកិច្ចការពារសុវត្ថិភាពទាំងបី និងដើម្បីផ្ញើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិច មកក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងឲ្យទាន់ពេលវេលាដេញថ្លៃ និងបានឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។
- ក្រុមការងារបានសហការជាមួយមន្ត្រី និងទីប្រឹក្សា នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ បញ្ចូលវគ្គរំលឹកឡើងវិញស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងគម្រោងឃុំ សង្កាត់ ក្រុង ស្រុក និងរាជធានី ខេត្ត ដែលបានរៀបចំនៅខេត្តកំពង់ចាម ព្រមទាំងបានជួយសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្នាក់ក្រោមជាតិដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធដែលទើបចូលបម្រើការងារថ្មី។

## ៣. បញ្ហាប្រឈមនានា

ក្នុងឆ្នាំនេះ ការសិក្សាផលប៉ះពាល់មានភាពយឺតយ៉ាវ ហេតុដល់ខែមេសាទើបមានខេត្តមួយចំនួនបានផ្ញើឯកសារ និងរបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងរបាយការណ៍វិធានការស្តីពីការពារជនជាតិដើមភាគតិច មកក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេស ដែលជាហេតុនាំឱ្យមានការដេញថ្លៃយឺតយ៉ាវ។ ដូចឆ្នាំមុនដែរ ខេត្តមួយចំនួនបានធ្វើការសិក្សាផលប៉ះពាល់បរិស្ថាននិងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច មុនធ្វើតម្រូវការសិក្សាគម្រោង និងធ្វើផែនការគម្រោង ដែលខុសនឹងនីតិវិធីដែលមានចែងក្នុងសៀវភៅ(ភីម) ជាហេតុនាំឱ្យមានការរៀបចំឯកសារម្តងហើយម្តងទៀត។ បញ្ហាប្រឈមមួយចំនួនដែលក្រុមការងារបានរកឃើញក្នុងការពិនិត្យឯកសារគម្រោង និងចុះទៅដល់ទីតាំងគម្រោងមានដូចខាងក្រោម៖

- ការបំពេញទម្រង់នានានៅមានភាពខ្វះចន្លោះច្រើន។
- ឃុំ សង្កាត់មួយចំនួនមិនបានរក្សាឯកសារច្បាប់ដើមរបស់គម្រោងនៅសាលាឃុំ សង្កាត់។

- ក្រុមប្រឹក្សាឃុំ សង្កាត់ភាគច្រើននៅមិនទាន់យល់ច្បាស់អំពីដំណើរការនៃការសិក្សា និងការរៀបចំឯកសារគម្រោងពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាពដីធ្លីនៅឡើយ។
- មន្ទីរជំនាញពាក់ព័ន្ធនៅមិនសូវយល់អំពីឯកសារគម្រោងរបស់ឃុំ សង្កាត់ ។
- ខ្វះមន្ត្រីទទួលបន្ទុកលើការងារផ្នែកបរិស្ថាន និងដីធ្លីរបស់គម្រោង ។
- ការចុះគាំទ្ររបស់មន្ត្រីបច្ចេកទេស និងមន្ត្រីគាំទ្រឃុំ សង្កាត់នៅមានកម្រិត ដោយសារមន្ត្រីនីមួយៗមានការងារស្មុគស្មាញច្រើន និងមិនបានទទួលការលើកទឹកចិត្ត។
- ការចុះគាំទ្ររបស់មន្ត្រីបច្ចេកទេស និងមន្ត្រីគាំទ្រឃុំ សង្កាត់នៅមិនទាន់បានជិតដល់នៅឡើយ។
- អ្នកទទួលការនៅមិនទាន់អនុវត្តតាមកិច្ចសន្យា ធ្វើឲ្យគម្រោងពន្យាពេល និងលើកទៅអនុវត្តន៍នៅឆ្នាំបន្តបន្ទាប់។
- ក្រុមប្រឹក្សាឃុំសង្កាត់មួយចំនួនពិបាកអញ្ជើញប្រជាពលរដ្ឋចូលរួមប្រជុំពិភាក្សាផលប៉ះពាល់គម្រោង ដោយសារម្ចាស់ដីមួយចំនួនចេញទៅប្រកបរបររកស៊ីនៅតំបន់ឆ្ងាយ។
- សម្ភារៈមានសភាពចាស់ៗលំបាកប្រើប្រាស់ក្នុងការសិក្សាគម្រោង។
- មន្ត្រីភាគច្រើនទើបចូលថ្មី មិនសូវយល់ពីការសិក្សាគម្រោង។
- មន្ទីរជំនាញពាក់ព័ន្ធទុករយៈពេលយូរក្នុងការបញ្ជាក់បច្ចេកទេសគម្រោង។
- មន្ត្រីគាំទ្រឃុំ សង្កាត់ជាមន្ត្រីទើបតែចូលបម្រើការងារថ្មី និងមិនធ្លាប់ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលមួយដងណាឡើយ ។
- មានការផ្លាស់ប្តូរមន្ត្រីជាញឹកញាប់ ធ្វើឱ្យខ្វះមន្ត្រីជួយការងារគម្រោង។

## ៤. ការសន្និដ្ឋាន

ក្នុងឆ្នាំ២០១៥នេះ ក្រុមការងារបានអនុវត្តការងារស្របទៅតាមផែនការសកម្មភាព ដែលបានគ្រោងទុកទាំងការពិនិត្យ និងផ្តល់យោបល់លើការអនុវត្តសុវត្ថិភាពបរិស្ថាន និងជនជាតិដើមភាគតិចទាំងការត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក និងរាជធានី ខេត្ត ទាំងការត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីគម្រោងមូលនិធិឃុំ សង្កាត់។ តាមរយៈការចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លី ឆ្នាំ២០១៤ និងបានជួបជាមួយអ្នកពាក់ព័ន្ធ រួមទាំងការចុះអង្កេតផ្ទាល់ដល់ទីតាំងគម្រោង ពិនិត្យឃើញថា ខេត្តមួយចំនួនដែលក្រុមការងារបានចុះត្រួតពិនិត្យគម្រោងក្នុងឆ្នាំ២០១៣ រួចរាល់ ឃើញថាគម្រោងដីធ្លីក្នុងឆ្នាំ២០១៤ បានកែប្រែក្នុងកម្រិតមួយតាមរបកគំហើញដែលបានឆ្លុះបញ្ចាំងក្នុងអំឡុងពេលចុះបេសកកម្ម។ ដោយឡែកខេត្តមួយចំនួនដែលមានការផ្លាស់ប្តូរមន្ត្រីជាញឹកញាប់នោះ ក្រុមការងារបានរកឃើញនូវកំហុសលើការបំពេញឯកសារមួយចំនួននៅតែមានខ្វះចន្លោះច្រើនមានដូចជា ការបំពេញទម្រង់ទី១ និងទី២ ក្រោយការសិក្សាផលប៉ះពាល់ដែលផ្ទុយពីគោលការណ៍ណែនាំរបស់សៀវភៅ(ភីម) គូរផែនទីអង្កេតដីធ្លីនៅមិនទាន់ត្រឹមត្រូវ ដោយមិនបានបង្ហាញក្បាលដីនីមួយៗ ដែលប៉ះពាល់និងមិនបានដាក់លេខកូដខ្នងផ្ទះ មិនបានបញ្ជាក់និងប្រថាប់ត្រានៅគ្រប់សន្លឹក និងចុះកាលបរិច្ឆេទលើស្នាមមេដៃក្នុងទម្រង់ទី២០.៥ ការចុះកាលបរិច្ឆេទលើទម្រង់របាយការណ៍ដោយកុំព្យូទ័រទុកជាមុន ទើបចុះសិក្សាដីធ្លីក្រោយ ចុះអង្កេតដីធ្លីមុនរៀបចំទម្រង់ទី១ និងទី២ ចុះអង្កេតក្រោយប្រជុំពិភាក្សានិងព្រមព្រៀង ការត្រួតពិនិត្យការសិក្សាព័ត៌មានគម្រោងដោយទីចាត់ការផែនការនិងវិនិយោគខេត្តបានផិកដោយកុំព្យូទ័រទុកជាមុន ឃុំសង្កាត់មួយចំនួនបាត់ឯកសារទម្រង់ផែនការសិក្សាគម្រោង ក្នុងរបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត(ទម្រង់ទី២០.៩)បំពេញទិន្នន័យមិនគ្រប់គ្រាន់ សរសេរកំណត់ហេតុប្រជុំទាំងពីរលើកមានខ្លឹមសារខ្លីពេកមិនអស់សេចក្តី។ ជាមួយគ្នានឹងការបំពេញឯកសារខ្វះចន្លោះនេះ ខេត្តនីមួយៗជួបនូវបញ្ហាមួយចំនួន ដូចជា ខ្វះឧបករណ៍សម្ភារៈប្រើប្រាស់សិក្សាគម្រោង មានមន្ត្រីមិនគ្រប់គ្រាន់ជួយគាំទ្រគម្រោង និងពុំសូវមានកិច្ចសហការពីមន្ទីរជំនាញពាក់ព័ន្ធ។ ដូចនេះ ដើម្បីពង្រឹងការអនុវត្តកិច្ចការពារ

សុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃគម្រោងមូលនិធិឃុំ សង្កាត់គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្តឱ្យបានឆ្លើយតបតាមគោលការណ៍ណែនាំដូចមានចែងក្នុងសៀវភៅ(ភីម) និងលិខិតបទដ្ឋានណែនាំនានា លុះត្រាតែមានការប្តេជ្ញាចិត្ត និងមានការយកចិត្តទុកដាក់ពីមន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធរបស់ខេត្តនីមួយៗ និងត្រូវតាមដានការត្រួតពិនិត្យការអនុវត្តគម្រោងជាមួយនិងអ្នកទទួលការ ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់ទីប្រឹក្សាក្រុង ស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស។

## ៥. អនុសាសន៍ និងសំណូមពរ

- ដើម្បីពង្រឹងការអនុវត្តសកម្មភាពកិច្ចការពារសុវត្ថិភាពទាំងបី ជាពិសេស កិច្ចការពារសុវត្ថិភាពដីធ្លី នៃគម្រោងមូលនិធិឃុំ សង្កាត់ និងដើម្បីឆ្លើយតបតាមគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅភីម និងលិខិតណែនាំនានា លុះត្រាតែបង្កើនការយកចិត្តទុកដាក់ពីមន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធ ជាពិសេស ការតាមដាន ត្រួតពិនិត្យពីសំណាក់ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាពង្រឹងសមត្ថភាព ទាំងការរៀបចំទុកដាក់ឯកសារ និងការអនុវត្តជាក់ស្តែង ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់ទីប្រឹក្សាក្រុង ស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត។
- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និង មន្ត្រីពាក់ព័ន្ធថ្នាក់ខេត្ត ត្រូវជួយពង្រឹងឱ្យមានកិច្ចសហការគ្នាល្អរវាងមន្ត្រីគាំទ្របច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត មន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ នៃទីចាត់ការផែនការ និងវិនិយោគខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចថ្នាក់ខេត្ត តាមរយៈការរៀបចំផែនការសិក្សាកិច្ចការពារសុវត្ថិភាពទាំងបីរួមគ្នា ការចុះសិក្សាគម្រោងរួមគ្នា និងការចូលរួមប្រជុំប្រចាំខែ ឬប្រជុំប្រចាំត្រីមាសរបស់កម្មវិធីវិនិយោគជាទៀងទាត់។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើនការយកចិត្តទុកដាក់ចំពោះការសិក្សា ការរៀបចំឯកសារគម្រោងឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានា ព្រមទាំងបង្កើននូវការតាមដាន ត្រួតពិនិត្យពេលអនុវត្តគម្រោង និងថែទាំលទ្ធផលគម្រោងឱ្យបានជាប់ជាប្រចាំ។
- មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបច្ចេកទេសទ្រឃុំសង្កាត់ត្រូវបង្កើនការចុះតាមដាន និងការត្រួតពិនិត្យលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឱ្យបានជិតដល់។
- ខេត្តគួរពិនិត្យលទ្ធភាពក្នុងផ្តល់ការហ្វឹកហ្វឺនបន្ថែមទៀតដល់ក្រុមប្រឹក្សាឃុំសង្កាត់ ដើម្បីឱ្យមានសមត្ថភាពក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីឱ្យបានត្រឹមត្រូវដោយខ្លួនឯង ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាក្រុង ទីប្រឹក្សាស្រុក ដើម្បីឱ្យពួកគេមានសមត្ថភាពក្នុងការជួយគាំទ្រឃុំ សង្កាត់។

## ៦. សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៦

- រៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ សម្រាប់ក្រុមការងារកិច្ចការពារសុវត្ថិភាព។
- រៀបចំធ្វើបច្ចុប្បន្នភាពនៃបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថាន និងបញ្ជីតំបន់ជនជាតិដើមភាគតិច។
- ចូលរួមតាមការអញ្ជើញរបស់ថ្នាក់ក្រោមជាតិក្នុងវគ្គរំលឹកឡើងវិញស្តីពីគោលការណ៍ណែនាំការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសាររបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត។
- ចុះតាមដានការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លី របស់ថ្នាក់ក្រោមជាតិជាក់ស្តែងនៅទីតាំងគម្រោង។

- ចុះតាមដានវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិច នៅតាមបណ្តាខេត្តនានា។
- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០១៦ ស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងក្របខណ្ឌគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត។
- ចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីនៃគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្តឆ្នាំ២០១៥។
- ចូលរួមសម្របសម្រួលជាមួយអង្គភាពនានាចំណុះលេខាធិការដ្ឋាន ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលានានាដល់មន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ។
- ចូលរួមសម្របសម្រួលជាមួយការិយាល័យពាក់ព័ន្ធនៃអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី និងទីប្រឹក្សាពាក់ព័ន្ធថ្នាក់ជាតិដើម្បីរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១៦ក្នុងគោលដៅដើម្បីគាំទ្រដល់ការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។
- រៀបចំរបាយកាយណ៍រីកចម្រើនប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប។

**រៀបចំដោយ**
**ក្រុមការងារកិច្ចការពារសុវត្ថិភាព**
**លេខាធិការដ្ឋាន គ.ជ.អ.ប**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី
លេខៈ ០៤១ រ.ប.ក./អ.គ.គ.ក

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦

**សូមគោរពជូន**

**ឯកឧត្តមអនុប្រធានប្រតិបត្តិ នៃលេខាធិការដ្ឋាន គ.ជ.អ.ប**

**តាមរយៈ៖** លោកប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី។

**កម្មវត្ថុ ៖** របាយការណ៍សង្ខេបស្ដីពីលទ្ធផលការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចប្រចាំឆ្នាំ២០១៥ ។

**យោង ៖** - សេចក្ដីសម្រេចលេខ ៧៨ សសរ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ស្ដីពីការបង្កើតក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃលេខាធិការដ្ឋាន គ.ជ.អ.ប។

- ផែនការសកម្មភាពរបស់ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ឆ្នាំ២០១៥។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាកិច្ចការមួយដ៏សំខាន់បំផុតដែលទាមទារនូវការយកចិត្តទុកដាក់ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងតម្រូវឲ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់មន្ត្រីរបស់ទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីការិយាល័យគាំទ្រឃុំ សង្កាត់នៅថ្នាក់ក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោងផងដែរ។ ក្នុងឆ្នាំ២០១៥នេះ ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានខិតខំបំពេញការងាររបស់ខ្លួនតាមផែនការសកម្មភាព និងថវិកាដែលបានកំណត់ដោយយកចិត្តទុកដាក់ និងមានការទទួលខុសត្រូវខ្ពស់ រហូតទទួលបានលទ្ធផលមានដូចខាងក្រោម៖

១. ក្រុមការងារបានសម្របសម្រួលជាមួយនាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ និងបានធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងឆ្នាំ២០១៥ ជារៀងរាល់ខែដែលថ្នាក់ក្រោមជាតិបានសិក្សាមុននឹងអនុវត្តន៍គម្រោង ក្នុងនេះមាន៖

ក). គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៥ សរុបមានចំនួន **១៦៦៧**គម្រោងនៃ**១៥៣៧**ឃុំ សង្កាត់ តម្រូវការសិក្សាបរិស្ថានសរុបចំនួន **៦៥០**គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន**៦២២**គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបមានចំនួន **៩០**គម្រោង។ គម្រោងដែលស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបមានចំនួន**៥៦០** និងគម្រោងដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចសរុបមានចំនួន **៩០**គម្រោង ។

ខ). គម្រោងមូលនិធិក្រុង ស្រុក នៅឆ្នាំ២០១៥ សរុបមានចំនួន២៤៨គម្រោង នៃ ១៨៥ក្រុង ស្រុក។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន ៩០គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន ៨គម្រោង តម្រូវការសិក្សាជនជាតិដើមភាគតិចសរុបមានចំនួន ១៨គម្រោង។ ចំនួនគម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបចំនួន ៨៣គម្រោង។

គ). គម្រោងមូលនិធិរាជធានី ខេត្ត ឆ្នាំ២០១៥ មានចំនួនសរុប ២៧០គម្រោងនៃ ២៤ខេត្ត ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន ៣០គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន ៣គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន ៧គម្រោង។ គម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបមានចំនួន ៣០គម្រោង។

២. បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថានក្នុងនេះមាន៖

ក). គម្រោងមូលនិធិឃុំ សង្កាត់ ផ្នែកបរិស្ថានបានចំនួនសរុប ៥៣៤គម្រោង ស្មើនឹង៩៣%នៃចំនួនសរុប ៥៧៤គម្រោង និងវិធានការការពារជនជាតិដើមភាគតិចពិនិត្យបានចំនួនសរុប ៧៨គម្រោង ស្មើនឹង ៨៦% នៃចំនួន៩០គម្រោង ។ គម្រោងបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុនៅមូលដ្ឋានមានចំនួន ៩ គម្រោង។

ខ).គម្រោងមូលនិធិក្រុង ស្រុក ផ្នែកបរិស្ថានបានចំនួនសរុប ៥៧គម្រោង ស្មើនឹង៦៩%នៃចំនួនសរុប៨៣ គម្រោង និងពិនិត្យវិធានការការពារជនជាតិដើមភាគតិចបានចំនួន ៨គម្រោង ស្មើនឹង៤៤%នៃចំនួន ១៨ គម្រោង ។

គ).បានពិនិត្យបរិស្ថានគម្រោងមូលនិធិខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានពិនិត្យបានចំនួនសរុប ២៩គម្រោង ស្មើនឹង៩៧%នៃចំនួនសរុប ៣០គម្រោង និងពិនិត្យគម្រោងជនជាតិដើមភាគតិចបានចំនួន ៥គម្រោង ស្មើ៧១%នៃគម្រោងសរុបចំនួន ៧គម្រោង។

៣. បានចុះត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីរបស់គម្រោង នៅទីចាត់ការផែនការ និងវិនិយោគខេត្តចំនួនប្រាំបួនខេត្ត ព្រមទាំងបានចុះទៅដល់ឃុំ សង្កាត់ និងទីតាំងគម្រោង។ បានត្រួតពិនិត្យគម្រោង ដីធ្លីសរុបចំនួន ១៦៩គម្រោង ស្មើនឹង៦៥%នៃគម្រោងមូលនិធិឃុំ សង្កាត់ ត្រូវការសិក្សាដីធ្លីសរុបចំនួន២៥៧គម្រោង។ ដំណើរការនៃការត្រួតពិនិត្យឯកសារ និងរបាយការណ៍ដីធ្លីនេះ នៅទីចាត់ការផែនការ និងវិនិយោគខេត្ត និងសាលាឃុំ សង្កាត់ ហើយបានផ្ទៀងផ្ទាត់របាយការណ៍ទាំងនោះ នៅតាមទីតាំងគម្រោង ដោយជួបជាមួយប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង។ បន្ទាប់ពីបញ្ចប់រាល់ការពិនិត្យឯកសារ ក្រុមការងារបានប្រជុំឆ្លុះបញ្ចាំងបង្ហាញពីលទ្ធផលដែលបានរកឃើញលើចំណុចខ្វះខាត និងផ្តល់អនុសាសន៍ ដល់អ្នកពាក់ព័ន្ធសម្រាប់កែលម្អនូវការអនុវត្តនៅឆ្នាំបន្ទាប់ទៀត។

៤. ថ្ងៃទី១៨-១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០១៥ ភ្ជាប់ជាមួយនិងវគ្គរំលឹកឡើងវិញស្តីពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់នៅខេត្តព្រះសីហនុ ដែលមានសមាសភាពចូលរួមជានាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីការិយាល័យផែនការ និងគាំទ្រគម្រោងឃុំ សង្កាត់ និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពខេត្ត សរុបចំនួន៥៧ នាក់ស្រី២នាក់។ គោលបំណងនៃកិច្ចប្រជុំ គឺដើម្បីកែលម្អនូវចំណុចខ្វះចន្លោះមួយចំនួន ដែលបានរកឃើញក្នុងរយៈពេលអនុវត្តការងារ១០ខែកន្លងមក និងឆ្លើយតបចំពោះតម្រូវការជាក់ស្តែងនៅថ្នាក់ក្រោមជាតិ ដោយផ្សារភ្ជាប់និងវគ្គរំលឹកឡើងវិញស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ រួមទាំងគម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ផងដែរ។

៥. នៅខេត្តកំពង់ចាមថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ បានផ្តល់វគ្គរំលឹកឡើងវិញស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត ដែលទើបចូលបម្រើការងារថ្មីមកពីរាជធានី ខេត្តទាំង២៥ សរុបចំនួន ៦២នាក់។ វគ្គនេះផ្សារភ្ជាប់ជាមួយវគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះគម្រោងហេដ្ឋារចនា សម្ព័ន្ធថ្នាក់ក្រោមជាតិ ដែលមានរយៈពេលប្រាំថ្ងៃ។ គោលបំណងនៃវគ្គនេះ គឺដើម្បីឆ្លើយតបក្នុងការជួយគាំទ្រដល់ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិ និងផ្តល់ចំណេះដឹង រួមទាំងបទពិសោធន៍លើការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។

តាមរយៈការពិនិត្យឯកសាររបាយការណ៍ ការចុះត្រួតពិនិត្យការងារជាក់ស្តែង ក្រុមការងារឃើញនូវបញ្ហាប្រឈមមួយចំនួនមានដូចខាងក្រោម៖

១. ការសិក្សាផលប៉ះពាល់បរិស្ថានបានពន្យាពេលវេលាយូរ រហូតដល់ខែមេសាទើបមានខេត្តមួយចំនួនបានផ្ញើបញ្ជីគម្រោង និងឯកសាររបាយការណ៍មកក្រុមការងារដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេស។

២. ការអនុវត្តគម្រោងឃុំ សង្កាត់ មួយចំនួនមានភាពមិនប្រក្រតី និងនៅតែមានភាពខ្វះចន្លោះច្រើន ដូចជាបានធ្វើការសិក្សាផលប៉ះពាល់បរិស្ថាននិងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច មុនធ្វើតម្រូវការសិក្សា និងធ្វើផែនការគម្រោង ដែលខុសនឹងនីតិវិធីដែលមានចែងក្នុងសៀវភៅ(ភីម) ជាហេតុនាំឱ្យមានការរៀបចំឯកសារម្តងហើយម្តងទៀត។

៣. ការបំពេញទម្រង់នានានៅមានភាពខ្វះចន្លោះច្រើន ឃុំ សង្កាត់មួយចំនួនមិនបានរក្សាឯកសារច្បាប់ដើមរបស់គម្រោងនៅសាលាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ភាគច្រើននៅមិនទាន់យល់ច្បាស់អំពីដំណើរការនៃការសិក្សា និងការរៀបចំឯកសារគម្រោងពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាពដីធ្លីនៅឡើយ។

៤. មន្ទីរជំនាញពាក់ព័ន្ធនៅមិនសូវយល់អំពីឯកសារគម្រោងរបស់ឃុំ សង្កាត់។

៥. ខ្វះមន្ត្រីទទួលបន្ទុកលើការងារផ្នែកបរិស្ថាន និងដីធ្លីរបស់គម្រោង ហើយការចុះគាំទ្ររបស់មន្ត្រីបច្ចេកទេស និងមន្ត្រីគាំទ្រឃុំ សង្កាត់នៅមានកម្រិត ដោយសារមានការងារស្មុគស្មាញច្រើន និងមិនបានទទួលការលើកទឹកចិត្ត។

៦.ឧបករណ៍ និងសម្ភារៈមានសភាពចាស់ៗលំបាកប្រើប្រាស់ក្នុងការសិក្សាគម្រោង។

៧. មន្ត្រីភាគច្រើនទើបចូលថ្មីមិនសូវយល់ពីការសិក្សាគម្រោង។

ដូច្នេះ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារនូវការចូលរួមយ៉ាងយកចិត្តទុកដាក់ពីមន្ត្រីពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងត្រូវសហការគ្នាល្អរវាងទីចាត់ការផែនការ និងវិនិយោគ និងមន្ទីរជំនាញពាក់ព័ន្ធដើម្បីពង្រឹងកិច្ចការពារសុវត្ថិភាពក្នុងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានីខេត្ត តាមរយៈការប្រជុំនានា ការបណ្តុះបណ្តាលវគ្គនានា ការចុះពិនិត្យតាមដានការអនុវត្តគម្រោង ក្នុងគោលដៅធានាបាននូវតម្រូវការអភិវឌ្ឍន៍ជាក់ស្តែងនៅមូលដ្ឋាន។

សូមភ្ជាប់មកជាមួយនូវរបាយការណ៍រីចំរើនប្រចាំឆ្នាំ២០១៥ ចំនួន០១ច្បាប់ តារាងឧបសម្ព័ន្ធ **៧.១** ឧបសម្ព័ន្ធ **៧.២** ឧបសម្ព័ន្ធ **៧.៣** និងឧបសម្ព័ន្ធ **៧.៤**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាបជាសេចក្តីរាយការណ៍ និងមានមតិណែនាំដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ប្រធានក្រុមការងារ

**ខោល យុទ្ធលី**

បានឃើញ និងសូមគោរពជូនឯកឧត្តម
មេត្តាជ្រាបជាសេចក្តីរាយការណ៍ ។
**ប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី**

**ន៍_គីមសាន**

បានឃើញ

**ចាន់ ថារិទ្ធ**
19/01/16

## ឧបសម្ព័ន្ធ៧.១ បញ្ជីសង្ខេបគម្រោងមូលនិធិឃុំសង្កាត់ទាំង២៣ខេត្តក្នុងឆ្នាំ ២០១៥

### ខេត្តទាំង២៤

| លេខកូដ | ឈ្មោះខេត្ត/ស្រុក | នួនឃុំសង្ក | ចំនួនគម្រោង | ចំនួនគម្រោងលើកឡើង ២០១៥ សម្រាប់ | | | | | | | តំរូវការសិក្សាសុវត្ថិភាព | | | ងតំបន់ឃ្លាំ | ឈ្មោះមន្ត្រីទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ផ្លូវ | ស្ពាន | ធារាសាស្ត្រ | អណ្តូង | សាលា | បង្គន់ | ផ្សេងៗ | បរិស្ថាន | ដីធ្លី | ជនជាតិ | | |
| 4 | **កំពង់ឆ្នាំង** | | | | | | | | | | | | | | |
| 401 | បរិបូណ៌ | 11 | 11 | 9 | 0 | 0 | 0 | 1 | 0 | 1 | 3 | 8 | 0 | 2 | ហង្ស ពិសី និងឡេង សំអេត |
| 402 | ជលគីរី | 5 | 6 | 4 | 0 | 1 | 0 | 0 | 0 | 1 | 6 | 6 | 0 | 5 | ហង្ស ពិសី និងឡេង សំអេត |
| 403 | ក្រុង កំពង់ឆ្នាំង | 4 | 4 | 4 | 0 | 0 | 0 | 0 | 0 | 0 | 1 | 1 | 0 | 0 | ហង្ស ពិសី និងឡេង សំអេត |
| 404 | កំពង់លែង | 9 | 7 | 7 | 0 | 0 | 0 | 0 | 0 | 0 | 2 | 2 | 0 | 6 | ហង្ស ពិសី និងឡេង សំអេត |
| 405 | កំពង់ត្រឡាច | 10 | 10 | 10 | 0 | 0 | 0 | 0 | 0 | 0 | 3 | 8 | 0 | 3 | ហង្ស ពិសី និងឡេង សំអេត |
| 406 | រលាប្អៀរ | 13 | 13 | 13 | 0 | 0 | 0 | 0 | 0 | 0 | 4 | 11 | 0 | 4 | ហង្ស ពិសី និងឡេង សំអេត |
| 407 | សាមគ្គីមានជ័យ | 9 | 11 | 8 | 0 | 1 | 2 | 0 | 0 | 0 | 0 | 7 | 0 | 0 | ហង្ស ពិសី និងឡេង សំអេត |
| 408 | ទឹកផុស | 8 | 8 | 7 | 0 | 1 | 0 | 0 | 0 | 0 | 4 | 7 | 0 | 4 | ហង្ស ពិសី និងឡេង សំអេត |
| សរុបរង | 8 | **69** | **70** | **62** | **0** | **3** | **2** | **1** | **0** | **2** | **23** | **50** | **0** | **24** | |
| 5 | **កំពង់ស្ពឺ** | | | | | | | | | | | | | | |
| 502 | ក្រុង ច្បារមន | 15 | 16 | 15 | 0 | 0 | 0 | 0 | 0 | 1 | 0 | 13 | 0 | 0 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនជាង |
| 501 | បរសេដ្ឋ | 5 | 5 | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនជាង |
| 503 | គងពិសី | 13 | 14 | 12 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនជាង |
| 504 | ឱរ៉ាល់ | 5 | 6 | 6 | 0 | 0 | 0 | 0 | 0 | 0 | 3 | 0 | 0 | 3 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនជាង |
| 505 | ឧត្តុង្គ | 15 | 16 | 12 | 1 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនជាង |
| 506 | ភ្នំស្រួច | 12 | 14 | 6 | 0 | 4 | 2 | 1 | 0 | 1 | 10 | 8 | 0 | 9 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនជាង |
| 507 | សំរោងទង | 15 | 16 | 13 | 2 | 0 | 1 | 0 | 0 | 0 | 6 | 0 | 0 | 6 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនជាង |
| 508 | ថ្ពង | 7 | 8 | 8 | 0 | 0 | 0 | 0 | 0 | 0 | 1 | 3 | 0 | 1 | សួស សុផល ចិន សាម៉េត និងអ៊ុន ប៊ុនជាង |
| សរុបរង | 8 | **87** | **95** | **77** | **3** | **7** | **4** | **1** | **0** | **2** | **19** | **24** | **0** | **19** | |
| 8 | **កណ្តាល** | | | | | | | | | | | | | | |
| 801 | កណ្តាលស្ទឹង | 18 | 20 | 16 | 0 | 4 | 0 | 0 | 0 | 0 | 0 | 8 | 0 | 0 | តេង រិទ្ធី |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 802 | កៀនស្វាយ | 8 | 8 | 8 | 0 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 2 | វ៉ាត រិទ្ធ និងទ្រី ប៊ុនហ៊ាង |
| 803 | ខ្សាច់កណ្តាល | 18 | 17 | 17 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | 0 | 0 | គៀង សុខណាត |
| 804 | កោះធំ | 11 | 11 | 9 | 1 | 1 | 0 | 0 | 0 | 0 | 0 | 9 | 0 | 0 | ហេង ង៉នលាង |
| 805 | លើកដែក | 7 | 7 | 4 | 0 | 3 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ម៉ុល ម៉ាលី |
| 806 | ល្វាឯម | 15 | 19 | 17 | 0 | 2 | 0 | 0 | 0 | 0 | 0 | 11 | 0 | 0 | លុន ឌុម និងទ្រី ប៊ុនហ៊ាង |
| 807 | មុខកំពូល | 7 | 7 | 7 | 0 | 0 | 0 | 0 | 0 | 0 | 2 | 1 | 0 | 2 | ឃឹម ផ្កា និងទ្រី ប៊ុនហ៊ាង |
| 808 | អង្គស្នួល | 10 | 11 | 10 | 0 | 1 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | មិន ភី |
| 809 | ពញាឮ | 11 | 11 | 11 | 0 | 0 | 0 | 0 | 0 | 0 | 1 | 6 | 0 | 0 | ចេវ ឈី |
| 810 | ស្អាង | 16 | 21 | 18 | 0 | 3 | 0 | 0 | 0 | 0 | 0 | 13 | 0 | 0 | ឃុត ផល្វា |
| 811 | ក្រុង តាខ្មៅ | 6 | 6 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ប៊ុន រមនី |
| | **11** | **127** | **138** | **123** | **1** | **14** | **0** | **0** | **0** | **0** | **5** | **53** | **0** | **4** | |
| **14** | **ព្រៃវែង** | | | | | | | | | | | | | | |
| 1401 | បាភ្នំ | 9 | 10 | 8 | 0 | 1 | 0 | 0 | 0 | 1 | 0 | 8 | 0 | 0 | ឈុន ណាត |
| 1402 | កំចាយមារ | 8 | 8 | 8 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | ឈុន ណាត |
| 1403 | កំពង់ត្របែក | 13 | 13 | 11 | 0 | 2 | 0 | 0 | 0 | 0 | 0 | 9 | 0 | 0 | ឈុន ណាត |
| 1404 | កញ្ជៀច | 8 | 9 | 6 | 0 | 2 | 0 | 1 | 0 | 0 | 0 | 2 | 0 | 0 | ឈុន ណាត |
| 1405 | មេសាង | 8 | 8 | 7 | 0 | 0 | 0 | 1 | 0 | 0 | 0 | 2 | 0 | 0 | ឈុន ណាត |
| 1406 | ពាមជរ | 10 | 10 | 7 | 0 | 3 | 0 | 0 | 0 | 0 | 3 | 4 | 0 | 3 | ឈុន ណាត |
| 1407 | ពាមរក៍ | 8 | 9 | 7 | 0 | 0 | 0 | 0 | 0 | 2 | 0 | 4 | 0 | 0 | សាង សានហ៊ី   និងឈុន ណាត |
| 1408 | ពារាំង | 9 | 12 | 10 | 0 | 2 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | ឈុន ណាត |
| 1409 | ព្រះស្តេច | 11 | 11 | 7 | 0 | 3 | 0 | 0 | 0 | 1 | 0 | 3 | 0 | 0 | ឈុន ណាត |
| 1410 | ក្រុង ព្រៃវែង | 3 | 4 | 2 | 0 | 2 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | ឈុន ណាត |
| 1411 | ពោធិ៍រៀង | 7 | 7 | 6 | 0 | 1 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | ឈុន ណាត |
| 1412 | ស៊ីធរកណ្តាល | 11 | 12 | 12 | 0 | 0 | 0 | 0 | 0 | 0 | 0 | 9 | 0 | 0 | ឈុន ណាត |
| 1413 | ស្វាយអន្ទរ | 11 | 11 | 11 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ឈុន ណាត |
